នាយកដ្ឋានរ៉ាប់រងកម្ពុជា
លេខ....០២៦.....ន.ធ.ក./សណ្ឋាន

គោលការណ៍ណែនាំ
ស្តីពី
កិច្ចព្រមព្រៀងអន្តរការីធានារ៉ាប់រង

ក្នុងគោលបំណងពង្រឹងគុណភាពនៃសេវាអន្តរការី និងធានាបាននូវភាពប្រកួតប្រជែងស្មើភាព និងតម្លាភាព ក្នុងការផ្តល់សេវាអន្តរការីធានារ៉ាប់រងជូនអ្នកប្រើប្រាស់ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ជើងសាធានារ៉ាប់រង ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង និងភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល ដោយអនុលោមតាមព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង, អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, អនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង, អនុក្រឹត្យលេខ ២៧៨ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការធានារ៉ាប់រងខ្នាតតូច ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន **នាយកដ្ឋានរ៉ាប់រងកម្ពុជា** (**ន.ធ.ក.**) សូមចេញគោលការណ៍ណែនាំស្តីពី "កិច្ចព្រមព្រៀងអន្តរការីធានារ៉ាប់រង" ដូចខាងក្រោម៖

១. មាតិកាអប្បរមានៃកិច្ចព្រមព្រៀងអន្តរការីធានារ៉ាប់រង

កិច្ចព្រមព្រៀងអន្តរការីធានារ៉ាប់រង គឺជាការព្រមព្រៀងផ្តល់សេវាអន្តរការីធានារ៉ាប់រងជាលាយលក្ខណ៍អក្សររវាងក្រុមហ៊ុនធានារ៉ាប់រង និងជើងសាធានារ៉ាប់រង ឬក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល។

កិច្ចព្រមព្រៀងអន្តរការីធានារ៉ាប់រងត្រូវរៀបចំឡើងដោយប្រើប្រាស់ភាសាខ្មែរឱ្យបានច្បាស់លាស់ មាននិមិត្តសញ្ញានិងត្រារបស់ក្រុមហ៊ុន និងត្រូវមានមាតិកាអប្បរមា តាមលំដាប់ដូចខាងក្រោម៖

- **តារាងមាតិកា**៖ បញ្ជាក់ពីលេខទំព័រនៃផ្នែកនីមួយៗឱ្យបានច្បាស់លាស់។

អគារលេខ ១៦៨ F (ជាន់ទី៦) ផ្លូវ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កម្ពុជា
Building # 168 F (6th Floor), St. 598, Sangkat Chraing Chamres 1,
Khan Russey Keo, Phnom Penh, Cambodia.
071 258 0896
gad@irc.gov.kh
www.irc.gov.kh

- **និយមន័យ៖** កំណត់អំពីនិយមន័យនៃវាក្យសព្ទដែលប្រើក្នុងកិច្ចព្រមព្រៀង ដោយនិយមន័យនៃវាក្យសព្ទទាំងនោះត្រូវមានសង្គតិភាព និងអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន និងសទ្ធានុក្រមធានាវ៉ាប់រង។
- **កម្មវត្ថុ៖** កំណត់អំពីកម្មវត្ថុនៃកិច្ចព្រមព្រៀង។ ចំពោះកិច្ចព្រមព្រៀងដៃគូជាមួយក្រុមហ៊ុនភ្នាក់ងារធានាវ៉ាប់រង ដែលជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវកំណត់ម៉ូឌែលសម្រាប់ការប្រកបអាជីវកម្មបើងកាសួរន។
- **សុពលភាព៖** កំណត់អំពីរយៈពេលនៃកិច្ចព្រមព្រៀង និងកាលបរិច្ឆេទចាប់ផ្តើមអនុវត្តកិច្ច-ព្រមព្រៀង។
- **សិទ្ធិនិងកាតព្វកិច្ច៖** កំណត់អំពីសិទ្ធិនិងកាតព្វកិច្ចរបស់គូភាគីនៃកិច្ចព្រមព្រៀង ដែលការកំណត់នេះមិនត្រូវប៉ះពាល់ដល់សិទ្ធិរបស់សាធារណជន ឬអ្នកប្រើប្រាស់សេវាធានាវ៉ាប់រង។
- **អត្ថប្រយោជន៍សម្រាប់អន្តរការីធានាវ៉ាប់រង៖** កំណត់អំពីអត្ថប្រយោជន៍ជាកម្រៃជើងសា លក្ខខណ្ឌបង្វិលសងកម្រៃជើងសា និងអត្ថប្រយោជន៍មិនមែនជាកម្រៃជើងសា។
- **ការទទួល និងដោះស្រាយសំណងធានាវ៉ាប់រង៖** កំណត់អំពីការទទួល និងដោះស្រាយសំណងធានាវ៉ាប់រង អនុលោមតាមគោលការណ៍ណែនាំស្តីពីការទទួល និងដោះស្រាយសំណងធានាវ៉ាប់រង។
- **ការការពារសុវត្ថិភាពព័ត៌មានឯកជន៖** កំណត់អំពីការការពារសុវត្ថិភាពព័ត៌មានឯកជនរបស់គូភាគីនៃកិច្ចព្រមព្រៀង អតិថិជន និងអ្នកប្រើប្រាស់សេវាធានាវ៉ាប់រង និងលក្ខខណ្ឌនៃការចែករំលែកព័ត៌មានឯកជនដល់តតិយជន។
- **ការដោះស្រាយវិវាទ៖** កំណត់អំពីការនាំយកវិវាទនៃកិច្ចព្រមព្រៀងអន្តរការីធានាវ៉ាប់រងទៅដូន **ន.ធ.ភ.** ដើម្បីសម្រុះសម្រួលធ្វើការដោះស្រាយ មុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ច ស្របតាមច្បាប់និងនីតិវិធីជាធរមាន។
- **ការបញ្ចប់កិច្ចព្រមព្រៀង៖** កំណត់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការបញ្ចប់កិច្ចព្រមព្រៀងមុនកាលកំណត់ឬដល់កាលកំណត់ លក្ខខណ្ឌដែលនាំឱ្យមានមោឃភាពនិងការបាត់បង់សិទ្ធិ ការទទួលខុសត្រូវរបស់ក្រុមហ៊ុនធានាវ៉ាប់រងចំពោះម្ចាស់បណ្ណសន្យាវ៉ាប់រងដែលត្រូវបានណែនាំ ឬលក់ផលិតផលធានាវ៉ាប់រងដោយអន្តរការីធានាវ៉ាប់រង និងកាតព្វកិច្ចជូនដំណឹងអំពីការបញ្ចប់កិច្ចព្រមព្រៀងអន្តរការីធានាវ៉ាប់រង ដល់អតិថិជន។
- **ដែនយុត្តាធិការ៖** កំណត់អំពីដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជាក្នុងការអនុវត្តកិច្ច-ព្រមព្រៀងអន្តរការីធានាវ៉ាប់រង។
- **ក្រមសីលធម៌វិជ្ជាជីវៈ៖** កំណត់អំពីការប្រកបវិជ្ជាជីវៈអន្តរការីធានាវ៉ាប់រងស្របតាមគោលការណ៍ណែនាំស្តីពីក្រមសីលធម៌វិជ្ជាជីវៈ។

ក្រៅពីចំណុចដែលមានកំណត់ខាងលើ គូភាគីអាចដាក់បន្ថែមនូវចំណុចផ្សេងបន្ថែមទៀតបាន ដោយមានការព្រមព្រៀងគ្នាជាមុន។

២. ការកំណត់អត្ថប្រយោជន៍សម្រាប់អន្តរការីធានារ៉ាប់រង

២.១. អត្ថប្រយោជន៍ជាកម្រៃជើងសា

អត្ថប្រយោជន៍ជាកម្រៃជើងសា សំដៅដល់សាច់ប្រាក់ដែលក្រុមហ៊ុនធានារ៉ាប់រងផ្តល់ជូនអន្តរការីធានារ៉ាប់រងសម្រាប់ការផ្តល់សេវាលក់ផលិតផលធានារ៉ាប់រង ឬសេវាណែនាំផលិតផលធានារ៉ាប់រង។

កម្រៃជើងសា ត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

កម្រៃជើងសាប្រចាំឆ្នាំ = អត្រាកម្រៃជើងសា x បុព្វលាភធានារ៉ាប់រងដុលប្រចាំឆ្នាំ

២.១.១. អត្រាកម្រៃជើងសា

អត្រាកម្រៃជើងសា ត្រូវបានកំណត់ដូចខាងក្រោម៖

ក. ការលក់ផលិតផលធានារ៉ាប់រងអាយុជីវិត៖

- អត្រាកម្រៃជើងសាសម្រាប់ឆ្នាំទី១៖ មិនលើសពី ៧០% នៃបុព្វលាភធានារ៉ាប់រងដុលប្រចាំឆ្នាំ
- អត្រាកម្រៃជើងសាសម្រាប់ឆ្នាំទី២ និងឆ្នាំទី៣៖ មិនលើសពី ៤០% នៃបុព្វលាភធានា-រ៉ាប់រងដុលប្រចាំឆ្នាំ
- អត្រាកម្រៃជើងសាសម្រាប់ឆ្នាំបន្តបន្ទាប់៖ មិនលើសពី ២០% នៃបុព្វលាភធានារ៉ាប់រងដុលប្រចាំឆ្នាំ។

ខ. ការលក់ផលិតផលធានារ៉ាប់រងទូទៅ និងខ្នាតតូចៈ អត្រាកម្រៃជើងសាមិនលើសពី **២០%** នៃបុព្វលាភធានារ៉ាប់រងដុលប្រចាំឆ្នាំ។

២.១.២. ការបង្វិលសងកម្រៃជើងសា

ការបង្វិលសងកម្រៃជើងសា អនុវត្តចំពោះតែការលក់ផលិតផលធានារ៉ាប់រងអាយុជីវិត។

ក. លក្ខខណ្ឌនៃការបង្វិលសងកម្រៃជើងសា

ការបង្វិលសងកម្រៃជើងសា ត្រូវអនុវត្តក្រោមលក្ខខណ្ឌដូចខាងក្រោម៖

- អតិថិជនបញ្ចប់កិច្ចសន្យាធានារ៉ាប់រងក្នុងរយៈពេលសាកល្បង
- អន្តរការីធានារ៉ាប់រងបំពានក្រមសីលធម៌វិជ្ជាជីវៈ ឬច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- អន្តរការីធានារ៉ាប់រងល្មើសនឹងកិច្ចព្រមព្រៀងអន្តរការីធានារ៉ាប់រង
- ការបង្វិលសងកម្រៃជើងសាមិនអនុវត្តចំពោះកិច្ចសន្យាធានារ៉ាប់រងដែលបានផ្តាក
- ការបង្វិលសងកម្រៃជើងសាមិនអនុវត្តចំពោះការលក់ផលិតផលធានារ៉ាប់រងដោយផ្ទាល់ណែនាំ។

ការបង្វិលសងកម្រៃជើងសាត្រូវគណនាតាមរូបមន្ត ដូចខាងក្រោម៖

កម្រៃជើងសាដែលត្រូវបង្វិលសង = កម្រៃជើងសាដែលបានទទួល × អត្រាបង្វិលសង

ខ. អត្រាបង្វិលសង

អត្រាបង្វិលសង ត្រូវបានកំណត់ដូចខាងក្រោម៖

- ១០០% នៃកម្រៃជើងសាដែលទទួលបានក្នុងឆ្នាំទី១
- ៥០% នៃកម្រៃជើងសាដែលទទួលបានក្នុងឆ្នាំទី២។

២.២. អត្ថប្រយោជន៍មិនមែនជាកម្រៃជើងសា

អត្ថប្រយោជន៍មិនមែនជាកម្រៃជើងសា សំដៅដល់អត្ថប្រយោជន៍មិនមែនជាសាច់ប្រាក់ដែលក្រុមហ៊ុនធានារ៉ាប់រងផ្តល់ជូនអន្តរការីធានារ៉ាប់រងសម្រាប់ការផ្តល់សេវាលក់ផលិតផលធានារ៉ាប់រង ឬសេវាណែនាំផលិតផលធានារ៉ាប់រងដែលអន្តរការីធានារ៉ាប់រងបានបំពេញតាមកិច្ចព្រមព្រៀង។

ក្រុមហ៊ុនធានារ៉ាប់រង អាចផ្តល់អត្ថប្រយោជន៍មិនមែនជាកម្រៃជើងសាឱ្យជើងសាធានារ៉ាប់រង ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង និងភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល រួមមានជាអាទិ៍៖

ក. ឧបករណ៍ ឬសម្ភារៈ ឬសេវាគាំទ្រការលក់ ឬការធ្វើអាបណកម្ម ដូចជាកុំព្យូទ័រ កម្មវិធីកុំព្យូទ័រ សម្ភារៈផ្សព្វផ្សាយ ឬសម្ភារៈការិយាល័យ។

ខ. ការធ្វើដំណើរកម្សាន្ត ការស្នាក់នៅ ការចូលរួមសន្និសីទ សិក្ខាសាលា ឬព្រឹត្តិការណ៍ផ្សេងៗ។

គ. ពានរង្វាន់ បណ្ណសរសើរ ឬការទទួលស្គាល់ផ្សេងៗ។

អត្ថប្រយោជន៍មិនមែនជាកម្រៃជើងសាដែលក្រុមហ៊ុនធានារ៉ាប់រងផ្តល់ជូនជើងសាធានារ៉ាប់រង ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង និងភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល មិនត្រូវមានតម្លៃលើសពី ៥% នៃបុព្វលាភធានារ៉ាប់រងជុំលសរុបប្រចាំឆ្នាំ។

៣. ការរក្សាទុកឯកសារ

ក្រុមហ៊ុនធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងមានកាតព្វកិច្ចរក្សាទុករាល់ឯកសារគណនេយ្យដែលពាក់ព័ន្ធទៅនឹងកម្រៃជើងសា និងអត្ថប្រយោជន៍មិនមែនជាកម្រៃជើងសាទាំងអស់របស់ខ្លួនឱ្យបានគង់វង្សក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃការបង្កើតឯកសារ។

៤. កាតព្វកិច្ចជូនដំណឹង

ក្រុមហ៊ុនធានារ៉ាប់រងត្រូវជូនដំណឹងមក **ន.ធ.ក.** ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីការកែប្រែ ឬបន្តកិច្ចព្រមព្រៀងអន្តរការីធានារ៉ាប់រង ជាមួយភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល ដោយភ្ជាប់ជាមួយកិច្ចព្រមព្រៀងដែលបានកែប្រែ ឬកិច្ចព្រមព្រៀងដែលមានសុពលភាព។

ជើងសាធានារ៉ាប់រង ឬក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ត្រូវជូនដំណឹងមក **ន.ធ.ក** ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការកែប្រែ ឬបន្តកិច្ចព្រមព្រៀងអន្តរការីធានារ៉ាប់រង ដោយភ្ជាប់ជាមួយកិច្ចព្រមព្រៀងដែលបានកែប្រែ ឬកិច្ចព្រមព្រៀងដែលមានសុពលភាព។

៥. ការអនុវត្ត

កិច្ចព្រមព្រៀងអន្តរការីធានាវ៉ាប់រង ដែលទទួលបានការអនុញ្ញាតពី **ន.ធ.ក.** មុនកាលបរិច្ឆេទអនុវត្តនៃគោលការណ៍ណែនាំនេះ ត្រូវបន្តអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនោះ រហូតដល់ថ្ងៃទី៣១ ខែធ្នូ គ.ស.២០២៦។ ក្រុមហ៊ុនធានាវ៉ាប់រង ជើងសាធានាវ៉ាប់រង និងក្រុមហ៊ុនភ្នាក់ងារធានាវ៉ាប់រង ត្រូវស្នើសុំកែសម្រួលកិច្ចព្រមព្រៀង មក **ន.ធ.ក.** ឱ្យបានមុនថ្ងៃទី៣០ ខែវិច្ឆិកា គ.ស.២០២៦។

ក្រុមហ៊ុនធានាវ៉ាប់រង ជើងសាធានាវ៉ាប់រង ក្រុមហ៊ុនភ្នាក់ងារធានាវ៉ាប់រង និងភ្នាក់ងារធានាវ៉ាប់រង ជារូបវន្តបុគ្គលទាំងអស់ ត្រូវអនុវត្តតាមខ្លឹមសារនៃគោលការណ៍ណែនាំនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីកាលបរិច្ឆេទចុះហត្ថលេខានេះតទៅ។ ក្នុងករណីមិនអនុវត្តតាមចំណុចណាមួយនៃគោលការណ៍ណែនាំនេះ ក្រុមហ៊ុនធានាវ៉ាប់រង ជើងសាធានាវ៉ាប់រង ក្រុមហ៊ុនភ្នាក់ងារធានាវ៉ាប់រង និងភ្នាក់ងារធានាវ៉ាប់រងជារូបវន្តបុគ្គល ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ថ្ងៃ**ពុធ** ៨រោច ខែ**ភទ្របទ** ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ **តុលា** គ.ស.២០២៦

អគ្គនាយក
និយ័តករធានាវ៉ាប់រកម្ពុជា

ម៉ូ ច័ន្ទគីរ៉ូ

ចម្លងជូន៖
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ*
- *ដូចចំណុច ៥*
  "ដើម្បីអនុវត្ត"
- *ឯកសារ កាលប្បវត្តិ*